**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

~~~~~~~

សាលាឧទ្ធរណ៍ភ្នំពេញ

~~~~~

សំណុំរឿងព្រហ្មទណ្ឌ

លេខ១៤៩០/០៩-១២-២០១៩

សាលដីកាលេខ៥០ ក្រIV "ណ"

១៥-០៦-២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្ដីពីការរៀបចំអង្គតុលាការ ដែលប្រកាសឲ្យប្រើតាមរាជក្រមលេខនស/រកម/០៧១៤/០១៥ចុះថ្ងៃទី១៦ខែកញ្ញា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ (៨ᴴ០០)ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម ... ជាប្រធានក្រុមប្រឹក្សា

លោក ... ជាចៅក្រមប្រឹក្សា

លោកស្រី ... ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម ... ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក ...

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៤៩០ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានជនជាប់ចោទ៖

១/.ឈ្មោះ ***វយស*** ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិវៀតណាម សាសនាព្រះពុទ្ធ ទីកន្លែងកំណើតប្រទេសវៀតណាម ទីលំនៅមុនពេលឃុំខ្លួន ភូមិទ្រាត្បូង ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មុខរបរកម្មករសំណង់ ឪពុកឈ្មោះ ... (រ) ម្ដាយឈ្មោះ ... (រ) ប្រពន្ធឈ្មោះ ...(រ) មានកូន០៣នាក់ ទោសពីមុនគ្មាន "ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ឆ្នាំង" (ប្ដឹងឧទ្ធរណ៍) ។

មានឈ្មោះ ... និងឈ្មោះ ...ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

២/.ឈ្មោះ **អបល** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិម៉ុងបារាំង ឃុំរលាប្អៀរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃុំខ្លួនភូមិម៉ុងបារាំង សង្កាត់រលាប្អៀរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មុខរបរលក់មីឆា ឪពុកឈ្មោះ...(រ) ម្ដាយឈ្មោះ ...(រ) ប្រពន្ធឈ្មោះ ...(រ) មានកូន០១នាក់ ទោសពីមុនគ្មាន "ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ឆ្នាំង" (ប្ដឹងឧទ្ធរណ៍) ។

មានឈ្មោះ ... និងឈ្មោះ ... ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

ជាប់ចោទពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ដល់ខែធ្នូ ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣/.ឈ្មោះ **បមករ** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ (មិនប្តឹងឧទ្ធរណ៍) ។

៤/.ឈ្មោះ **លសខន** ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ (មិនប្តឹងឧទ្ធរណ៍) ។

៥/.ឈ្មោះ **យសអ** ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ (មិនប្តឹងឧទ្ធរណ៍) ។

## អង្គហេតុនៃរឿងមានដូចតទៅ

***សកម្មភាព***ប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទីៈ

កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង១៤និង០០នាទី នៅចំណុចផ្លូវជាតិលេខ៥៣ ស្ថិតក្នុងភូមិស្រែតាដៃលិច ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំ កម្លាំងអធិការនគរបាលស្រុកទឹកផុស សហការជាមួយកម្លាំងជំនាញការិយាល័យប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបបទល្មើសជាក់ស្តែង០១ករណី គឺករណីជួញដូររក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបន្តចាប់ខ្លួនរហូតដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ ជាលទ្ធផលឃាត់បានជនជាប់ចោទចំនួន០៥នាក់ គឺឈ្មោះ **បមករ**, ឈ្មោះ **លសខន**, ឈ្មោះ ..., ឈ្មោះ **អបល**និងឈ្មោះ ***វយស*** និងដកហូតវត្ថុតាងមាន ម្សៅក្រាមពណ៌សថ្លា ជាសារធាតុញៀនមេតំហ្វេតាមីនសរុបចំនួន ៩៦កញ្ចប់ សរុប(ទម្ងន់ ២៧០,១៦ក្រាម) ថ្នាំញៀនប្រភេទ WY ចំនួន១៨២គ្រាប់ ទម្ងន់(១៩,៦០ក្រាម) ទូរស័ព្ទចំនួន០៤គ្រឿង និងម៉ូតូចំនួន០២គ្រឿង ចំណែកឈ្មោះ **យសអ** បានគេចខ្លួនបាត់ ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ៦៣ "ឃ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ត្រង់ចំណុចនៃសេចក្តីសម្រេចដូចតទៅៈ

១-ជនជាប់ចោទ

ក/.ឈ្មោះ ***វយស*** ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់១៥(ដប់ប្រាំ)ឆ្នាំពីបទរក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ដល់ខែធ្នូ ឆ្នាំ២០១៨។

ខ/.ឈ្មោះ **អបល**ភេទប្រុស អាយុ២៣ឆ្នាំ

គ/.ឈ្មោះ **បមករ** ភេទប្រុស អាយុ២៨ឆ្នាំ

ឃ/.ឈ្មោះ **លសខន** ភេទស្រី អាយុ២៣ឆ្នាំ

ង/.ឈ្មោះ **យសអ** ភេទប្រុស អាយុ៣៧ឆ្នាំ

មានពិរុទ្ធភាពពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ដល់ខែធ្នូ ឆ្នាំ២០១៨ ។

២-ផ្តន្ទាទោសជនជាប់ចោទ៖

ក/.ឈ្មោះ **វយស** ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់១៥(ដប់ប្រាំ)ឆ្នាំ ពីបទរក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ដល់ខែធ្នូ ឆ្នាំ២០១៨ ។

ខ/.ឈ្មោះ **អបល** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៤(បួន)ឆ្នាំ។

គ/.ឈ្មោះ **បមករ** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២(ពីរ)ឆ្នាំ និង ០៦(ប្រាំមួយ)ខែ។

ឃ/.ឈ្មោះ **លសខន** ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២(ពីរ)ឆ្នាំ និង ០៦(ប្រាំមួយ)ខែ ។

ង/.ឈ្មោះ **យសអ** ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣(បី)ឆ្នាំ។

**ពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ដល់ខែធ្នូ ឆ្នាំ២០១៨ ។

៣.បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ **យសអ** ដែលមានសាវតារជាតិខាងលើ។

៤.រឹបអូសវត្ថុតាងមានក្នុងសាលដីកាបង្គាប់ឲ្យតម្កល់វត្ថុតាងលេខ ២៤៨៣ អ.យ/២០១៨ តាមបញ្ញត្តិមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា៦២នៃក្រមព្រហ្មទណ្ឌ ។

៥.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ចំពោះមុខជនជាប់ចោទឈ្មោះ**វយស**, ឈ្មោះ**អបល**, ឈ្មោះ**បមករ** និងឈ្មោះ**លសខន**។ កំបាំងមុខជនជាប់ចោទឈ្មោះ**យសអ** និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ទុកសិទ្ធិឲ្យប្តឹងទាស់និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍លេខ៤៩ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ **វយស** ក្នុងការប្តឹងឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៦៣ "ឃ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍០៨ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **អបល** ក្នុងការប្ដឹងឧទ្ធរណ៍មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៦៣ "ឃ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

**បានឃើញ**របាយការណ៍រឿងចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

**បានឃើញ**សេចក្ដីសន្និដ្ឋានចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ របស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ ***វយស*** ឆ្លើយថា ខ្លួនប្ដឹងឧទ្ធរណ៍នេះ ដោយសារទណ្ឌកម្មធ្ងន់ធ្ងរពេក។ ខ្លួនសុំឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោសមកត្រឹមចំនួន៧(ប្រាំពីរ)ឆ្នាំ ៦(ប្រាំមួយ)ខែ។ គ្រឿងញៀនមិនមែនជារបស់ខ្លួនទេ គឺជារបស់ឈ្មោះ **យសអ** ផ្ញើរឲ្យខ្លួនរក្សាទុក។ ពេលផ្ញើរខ្លួនមិនដឹងថាជាគ្រឿងញៀនទេ លុះពេលសមត្ថកិច្ចឃាត់ខ្លួន ហើយបើកកញ្ចប់បញ្ញើនោះ ទើបដឹងថាជាគ្រឿងញៀន។ ការផ្ញើកញ្ចប់ឥវ៉ាន់នោះឈ្មោះ **យសអ** ធ្លាប់បានឲ្យលុយខ្លួនចំនួន ១០០ដុល្លារ បានពីរលើកសរុបចំនួន ២០០ដុល្លារ។ ខ្លួនមិនបានជួញដូរគ្រឿងញៀនទេ។ គ្រឿងញៀននោះ កូនចៅរបស់ឈ្មោះ **យសអ** ជាអ្នកយកទៅលក់ឲ្យគេ ខ្លួនមិនដឹងទេ ចំណែកលុយលក់ទិញរបស់ពួកគេទូទាត់គ្នាយ៉ាងណានោះ ខ្លួនមិនបានដឹងមិនបានទទួលដែរ។ ខ្លួនស្គាល់ឈ្មោះ **យសអ** ប្រហែល០១ឆ្នាំ ពេលខ្លួនដើរលេង។

-ជនជាប់ចោទឈ្មោះ **អបល** ខ្លួនប្ដឹងឧទ្ធរណ៍នេះ ដោយសារទណ្ឌកម្មធ្ងន់ធ្ងរពេក។ ខ្លួនសុំឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោសមកត្រឹមចំនួន២ (ពីរ)ឆ្នាំ ព្រោះខ្លួនមិនបានជួញដូរគ្រឿងញៀនទេ ខ្លួនត្រូវបានឈ្មោះ **យសអ** ប្រើឲ្យយកគ្រឿងញៀនទៅប្រគល់ឲ្យគេ ហើយឈ្មោះ **យសអ** ឲ្យថ្នាំញៀនមកខ្លួនប្រើប្រាស់។ ខ្លួនប្រើប្រាស់គ្រឿងញៀនប្រហែល ២-៣ឆ្នាំ ហើយឈ្មោះ **យសអ** ប្រើខ្លួនឲ្យយកគ្រឿងញៀនទៅប្រគល់ឲ្យគេចំនួន០២ដង ក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្ដង។ ខ្លួនសំណូមពរសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសចំនួន២ (ពីរ)ឆ្នាំ ដោយសុំដាក់ទោសតែ០២ឆ្នាំបានហើយ ដើម្បីឆាប់បានចេញមកជួយរកស៊ីចិញ្ចឹមកូន។

-តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា បណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ ***វយស*** និងឈ្មោះ **អបល** ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ផ្អែកតាមមាត្រា៣៥៧ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ រឿងក្ដីនេះឃើញថាមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទដូចការចោទប្រកាន់របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ព្រោះជាបទល្មើសជាក់ស្ដែង ហើយសមត្ថកិច្ចបានដកហូតបានគ្រឿងញៀនពីឈ្មោះ ***វយស*** ម៉ាទឹកកកចំនួន ២,៨៣ក្រាម និងថ្នាំយ៉ាម៉ាចំនួន១៨២ គ្រាប់ ស្មើនឹង ១៩,៦០ ក្រាម ហើយដកហូតគ្រឿងញៀនពីឈ្មោះ

**អបល** មានចំនួន៦កញ្ចប់ ស្មើនឹង ១៧,៥៧ក្រាម។ តាមលទ្ធផលកោសល្យវិច័យឃើញថា ថ្នាំញៀនដែលដកហូតបានពីឈ្មោះ **វយស** ជាប្រភេទមេតំហ្វេតាមីនមានសារធាតុសុទ្ធ ៧៩,៩៩% នៃទម្ងន់សរុប ប្រភេទម៉្សៅក្រាមថ្លាស្មើនឹង ២០០,៦៧ ក្រាម និងថ្នាំគ្រាប់មានបរិមាណសុទ្ធ ១៧.០៤% ស្មើនឹង ៣,៣៣ក្រាម សរុបប្រភេទមេតំហ្វេតាមីនមានសារធាតុសុទ្ធ២០៤ក្រាម។ វត្ថុតាងដែលដកហូតបានពីជនជាប់ចោទឈ្មោះ **អបល** មាន៨០,២៩ % នៃទម្ងន់សរុបស្មើនឹង១៤,១០ក្រាម មេតំហ្វេតាមីនសុទ្ធ។ ជនជាប់ចោទទាំងពីរនាក់បានឆ្លើយទទួលស្គាល់កំណត់ហេតុដកហូតវត្ថុតាងរបស់សមត្ថកិច្ច។ តំណាងមហាអយ្យការយល់ឃើញថា ការប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ **វយស** ល្មើសនឹងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រង់ចំណុចផ្តន្ទាទោសពី ១០ឆ្នាំទៅ២០ឆ្នាំ និងពិន័យជាទឹកប្រាក់ចំនួន ២០.០០០.០០០ រៀល ទៅ ៤០.០០០.០០០ រៀល ចំណែកជនជាប់ចោទឈ្មោះ **អបល** ល្មើសនឹងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រង់ចំណុចផ្តន្ទាទោសពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាទឹកប្រាក់ចំនួន ៤.០០០.០០០ រៀល ទៅ ១០.០០០.០០០ រៀល។ សាលក្រមរបស់សាលាដំបូងសម្រេចមានការយល់ឃើញ និងសំអាងហេតុត្រឹមត្រូវហើយ ហេតុដូច្នេះតំណាងអយ្យការសូមឲ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ សម្រេចតម្កល់សាលក្រមសាលាដំបូងខេត្តកំពង់ឆ្នាំងទុកជាបានការ ។

-លោក ... ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ដោយសារតែកូនក្តីខ្លួនរបស់ខ្លួនខ្វះការយល់ដឹងជ្រៅជ្រះ និងមានជីវភាពក្រីក្រផង ទើបនាំឲ្យប្រព្រឹត្តខុសបែបនេះ ហេតុដូច្នេះសំណូមពរសុំឲ្យក្រុមប្រឹក្សាមេត្តជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនឲ្យបានទាបបំផុត ដោយក្តីអនុគ្រោះ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបាយការណ៍

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍យល់ឃើញថា

១.ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៩ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ **វយស** និងពាក្យបណ្តឹងឧទ្ធរណ៍០៨ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **អបល** ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌលេខ៦៣ "ឃ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំងត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ យោងតាមមាត្រា៣៧៣ និងមាត្រា ៣៧៥ មាត្រា៣៧៦ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចឲ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍

ទទួលយកសំណុំរឿងព្រហ្មទណ្ឌលេខ១៤៩០ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ មកធ្វើការជំនុំជម្រះជាសមត្ថកិច្ច ។

២.នាពេលសវនាការជនជាប់ចោទឈ្មោះ **វយស** ឆ្លើយថាការដែលខ្លួនប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់សាលាដំបូងខេត្តកំពង់ឆ្នាំង គឺខ្លួនចង់ស្នើសុំឲ្យសាលាឧទ្ធរណ៍ភ្នំពេញជួយបន្ថយទោសមកត្រឹមជាប់ពន្ធនាគាររយៈពេល៧(ប្រាំពីរ)ឆ្នាំ ៦(ប្រាំមួយ)ខែ រីឯជនជាប់ចោទឈ្មោះ **អបល** ឆ្លើយថាការដែលខ្លួនប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់សាលាដំបូងខេត្តកំពង់ឆ្នាំង គឺខ្លួនចង់ស្នើសុំឲ្យសាលាឧទ្ធរណ៍ភ្នំពេញជួយបន្ថយទោសមកត្រឹមជាប់ពន្ធនាគាររយៈពេល២(ពីរ)ឆ្នាំ។ ការស្នើសុំនេះ ពុំមានមូលហេតុត្រឹមត្រូវ ព្រោះថាទណ្ឌកម្មពន្ធនាគាររយៈពេល១៥(ដប់ប្រាំ)ឆ្នាំ ចំពោះជនជាប់ចោទឈ្មោះ **វយស** និងចំនួន៤(បួន)ឆ្នាំ ចំពោះជនជាប់ចោទឈ្មោះ **អបល** ដែលសាលាដំបូងខេត្តកំពង់ឆ្នាំងបានប្រកាសចំពោះជនជាប់ចោទ គឺមានលក្ខណៈសមស្របទៅនឹងបរិមាណជាតុសុទ្ធនៃគ្រឿងញៀនទម្ងន់ ២០៤,០១៧ ក្រាមដែលសមត្ថកិច្ចដកហូតបានពីជនជាប់ចោទឈ្មោះ **វយស** និងទម្ងន់ ១៤,១០៦ក្រាម ដែលសមត្ថកិច្ចដកហូតបានពីជនជាប់ចោទឈ្មោះ **អបល**។

៣.ផ្អែកតាមសំអាងហេតុខាងលើ ឃើញថា សំអាងហេតុ និងសេចក្តីសម្រេចក្នុងសាលក្រមព្រហ្មទណ្ឌលេខ៦៣ "ឃ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង គប្បីសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ សម្រេចបដិសេធពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងពីររូប ចោលជាអសារបង់។

៤.តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា បទល្មើសជាក់ស្តែងដែលសមត្ថកិច្ចដកហូតគ្រឿងញៀនបានពីជនជាប់ចោទទាំងពីររូប ហើយសាលក្រមរបស់សាលាដំបូងខេត្តកំពង់ឆ្នាំង សម្រេចមានលក្ខណៈត្រឹមត្រូវ ដូច្នេះសុំឲ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមនេះទុកជាបានការ។ ការស្នើសុំនេះ មានមូលហេតុត្រឹមត្រូវ ផ្អែកតាមសំអាងហេតុខាងលើ។

៥.មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីដ្ឋានថា កូនក្តីខ្លួនគ្មានការយល់ដឹងជ្រៅជ្រះ ទើបធ្លាក់ក្នុងការអូសទាញរបស់ឈ្មោះ **យសអ** ហេតុដូច្នេះ សុំឲ្យក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនទាំងពីររូប ។ ការស្នើសុំនេះ ពុំមានមូលហេតុត្រឹមត្រូវផ្អែកតាមសំអាងហេតុខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១.បដិសេធពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៩ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ **វយស** និងពាក្យបណ្តឹងឧទ្ធរណ៍០៨ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **អបល** ចោលជាអសារបង់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៦៣ "ឃ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ទុកជាបានការ។

៣.បន្តការឃុំខ្លួនជនជាប់ចោទទាំងពីររូបតាមច្បាប់។

៤.សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទ ទុកសិទ្ធិឲ្យប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា... | ហត្ថលេខា .... | ហត្ថលេខា... |